**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រ ហេង សំរិន ប្រធានរដ្ឋសភា**

**និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ **មមែ** សប្តស័ក ព.ស ២៥៥៩ គ.ស ២០១៥ នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមចូលរួមអបអរសាទរយ៉ាងក្លៀវក្លា ចំពោះលទ្ធផលដ៏ត្រចះត្រចង់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ ដែលបានជ្រើសតាំង **សម្តេចអគ្គមហាពញាចក្រ** ជាថ្មីម្តងទៀត ជាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមប្រសិទ្ធពរជ័យ មហាប្រសើរជូន **សម្តេច** និង**លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** ជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងទទួលបានជោគជ័យថ្មីៗ ថែមទៀត ក្នុងបេសកកម្មបម្រើជាតិមាតុភូមិ ដឹកនាំស្ថាប័ននីតិប្បញ្ញត្តិ កសាងនីតិរដ្ឋនាំប្រទេសជាតិឆ្ពោះទៅរកសុខសន្តិភាព និងអភិវឌ្ឍន៍មាតុភូមិកម្ពុជាឲ្យបានថ្កុំថ្កើង សម្បូររុងរឿងសមតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទូទាំងប្រទេស ជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចអគ្គមហាពញាចក្រ** និង**លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**